# មេរៀនទី ៩០៖ អ័ប៊ីកែលបង្កើតសេចក្ដីសុខសាន្ត

## ១ សាំយូអែល ២៥៖ ១-៣៥

**មេរៀនសម្រាប់គ្រូ** ( *យូធូបលីង* )៖ https://youtu.be/eSiMGOjlWD8

**រឿងនៅក្នុងព្រះគម្ពីរសម្រាប់កុមារ៖** https://youtu.be/fPcuv2tZrPc

**គោលបំណង៖** ព្រះជាម្ចាស់បាននាំមកនូវសេចក្ដីសុខសាន្ត។

**ខគម្ពីរចងចាំ៖** ម៉ាថាយ ៥៖៩ *"មានពរហើយ អស់អ្នកដែលផ្សះផ្សាគេ ដ្បិតអ្នកទាំងនោះនឹងបានហៅ ជាកូនរបស់ព្រះ។"*

**ចំរៀង** ( *យូធូបលីង* )៖

១. ស្ដេចលើស្ដេច https://youtu.be/CPBqHYVwm3M
២. ខ្ញុំចង់រីកចម្រើន https://youtu.be/fxp8B9SaXEU
៣. ព្រះយេហូវ៉ាតាមការពារ https://youtu.be/22Pta-n7GWM

### ១. អធិស្ឋាន

### ២. ចំរៀង ( *រើសចំរៀងខាងលើ១បទហើយច្រៀងជាមួយសិស្ស* )

### ៣. ល្បែងកំសាន្ត «ជ្រុង»

១. ដាក់លេខជ្រុងនៃថ្នាក់រៀន ១-៤
២. រើសកុមារម្នាក់មកបិទភ្នែកហើយគ្រូត្រូវបិទភ្នែករបស់គាត់
៣. ឲ្យកុមារទាំងអស់រត់រកជ្រុងដែលគេគិតថាជ្រុងនោះនឹងនាំមកនូវសេចក្ដីសុខសាន្ត
៤. កុមារដែលត្រូវគ្រូបិទភ្នែកនោះនឹងត្រូវធ្វើការជ្រើសរើសជ្រុងមួយ។ កុមារដែលរើសឈរនៅជ្រុងដែលអ្នក បិទភ្នែករើសនឹងចាញ់ល្បែងនេះ ហើយឲ្យពួកគេអង្គុយនៅជ្រុងម្ខាង។
៥. បន្តលេងល្បែងនេះ ៣ដង ដោយអ្នកបិទភ្នែកនៅដដែល ហើយកុមារណាដែលអាចនៅបន្តលេងល្បែងនេះរហូតដល់ចប់ នឹងឈ្នះល្បែងនេះ។
៦. បន្ទាប់ពីលេងល្បែងនេះចប់សូមពន្យល់កុមារថា ពួកគេប្រហែលជាគិតថាជ្រុងមួយមានសន្តិភាពជាងជ្រុងមួយទៀត។ ប៉ុន្តែតាមពិត សន្តិភាពពិតប្រាដកគឺមកតែពីព្រះមួយប៉ុណ្ណោះ។

### ៤. ការណែនាំមេរៀន

តើអ្នកមានអារម្មណ៍ដូចម្ដេចនៅពេលដែលអ្នកឈ្លោះជាមួយមិត្តភក្តិ បងប្អូនប្រុសឬស្រីរបស់អ្នកនោះ? ឬក៏ តើអ្នកមានអារម្មណ៍ដូចម្ដេច នៅពេលដែលនរណាម្នាក់និយាយពាក្យមិនសមរម្យមកកាន់អ្នក? ឈ្មោះមួយនៃឈ្មោះទាំងអស់របស់ព្រះយេស៊ូវនោះគឺ ស្ដេចនៃសន្តិភាព។ ព្រះចង់ឲ្យយើងមានសេចក្ដីសុខសាន្តជំនួសឲ្យការឈ្លោះប្រកែក ឬក៏ការខឹងសម្បានឹងគ្នា។ តើអ្នកគិតថា អ្នកនៅតែអាចរក្សាសន្តិភាពបានជាមួយនឹងអ្នកដែលធ្វើអាក្រក់ដាក់អ្នកបានដែរឬទេ? ថ្ងៃនេះ យើងនឹងរៀនអំពីបុរសម្នាក់ ដែលគាត់ស្ទើរតែបង្កឲ្យមានការឈ្លោះប្រកែកគ្នាដោយសារតែកំហឹងរបស់គាត់។

## ៥. រឿងនៅក្នុងព្រះគម្ពីរ

ដាវីឌបានរស់នៅតាមទីជនបទជាច្រើន ដោយសារគាត់ព្យាយាមរត់គេចពីស្តេចសូល ដែលនៅតែចង់សម្លាប់គាត់ដោយសារការច្រណែន។ ថ្ងៃមួយ ដាវីឌនិងទាហានរបស់គាត់បានទៅបោះតង់ស្នាក់នៅក្បែរផ្ទះបុរសម្នាក់ដែលមានឈ្មោះថា ណាបាល។ នៅជំនាន់របស់ដាវីឌ វាជារឿងធម្មតាទេ ក្នុងការយកហ្វូងសត្វរបស់ ណាបាលទៅធ្វើជាអាហារ ដោយមិនចាំបាច់សុំការអនុញ្ញាត្តិពីណាបាលនោះ។ ប៉ុន្តែដាវីឌគឺជាបុរសដ៏ល្អ គាត់បានប្រាប់ទាហានរបស់គាត់មិនឲ្យយកអ្វីទាំងអស់ ដែលជាកម្មសិទ្ធិរបស់ណាបាលជាដាច់ខាត។ ហើយនៅចំពោះមុខ ដាវីឌ និងទាហានរបស់គាត់បានជួយការពារហ្វូងសត្វរបស់ណាបាលពីពួកចោរទៀតផង។

ប៉ុន្មានថ្ងៃក្រោយមក ដាវីឌបានសុំសត្វខ្លះពីណាបាល ដើម្បីធ្វើជាម្ហូបអាហារសម្រាប់ទាហានរបស់គាត់ ដោយលោកបានជួយការពារហ្វូងសត្វរបស់ណាបាលច្រើនថ្ងៃមកហើយ។ ប៉ុន្តែណាបាលមានចិត្តឆេវឆាវចំពោះដាវីឌ ហើយមិនព្រមឲ្យអាហារទៅដាវីឌទេ។ វាគឺពិតជាធ្វើឲ្យដាវីឌខឹងខ្លាំណាស់។ ដាវីឌខឹងខ្លាំងណាស់ ហើយក៏បានលើកទ័ពបម្រុងនិងវាយជាមួយទ័ពរបស់ណាបាល។

ប៉ុន្តែណាបាលមានប្រពន្ធដ៏ឆ្លាតវៃម្នាក់ឈ្មោះថា អ័ប៊ីកែល។ នាងបាននាំយកអាហារជាច្រើន ទៅឲ្យដាវីឌនិងទាហានរបស់គាត់ ហើយបានសុំគាត់កុំឲ្យវាយប្រហារផ្ទះរបស់ណាបាល ព្រោះព្រះមិនសព្វព្រះទ័យឡើយ។ នេះជាការរារាំងដាវីឌមិនឲ្យច្បាំងនឹងណាបាល។

អ័ប៊ីកែល គឺជាអ្នកបង្កើតសន្តិភាព។ នាងបានឃាត់ដាវីឌមិនឲ្យប្រយុទ្ធ ហើយរក្សាដាវីឌឲ្យមានសន្តិភាពជាមួយណាបាល។ ពេលណាបាលដឹងថាអ័ប៊ីកែលបានផ្តល់អាហារឲ្យដាវីឌនិងទាហានរបស់ដាវីឌ គាត់ខឹងយ៉ាងខ្លាំង! ណាបាលខឹងខ្លាំងរហូតដល់ថ្នាក់គាំងបេះដូង ហើយគាត់ក៏ស្លាប់បាត់ទៅ។

ពេលយើងមានចិត្តខឹង វាមិនត្រឹមតែមិនល្អសម្រាប់រាងកាយរបស់យើងនោះទេ តែក៏អាក្រក់សម្រាប់ព្រលឹងយើងដែរ។ មួយរយៈក្រោយមក ពីព្រោះតែតែដាវីឌពិតជាដឹងគុណដល់អ័ប៊ីកែល ដែលបានជួយបញ្ឈប់កំហឹងរបស់គាត់ ដាវីឌសប្បាយចិត្តជាខ្លាំងដែលអ័ប៊ីកែលបានបញ្ឈប់គាត់កុំឲ្យមានចិត្តខឹង ហើយរក្សាគាត់ឲ្យមានសន្តិភាព ដូច្នេះគាត់បានសំរេចចិត្ត រៀបការជាមួយនាងបន្ទាប់ពីប្តីរបស់នាងស្លាប់ទៅ។

ព្រះចង់ឲ្យយើងមានសន្តិភាព។ ព្រះចង់ឱ្យយើងជួយអ្នកដទៃក្នុងការរក្សាសន្តិភាពរបស់ពួកគេ។ តើអ្នកនឹងផ្លាស់ប្រែចិត្តដែលខឹងស្អប់ ទៅជាដួងចិត្តដែលមានសន្តិភាពដែរឬទេ?

## ៦. សំនួរពិភាក្សា

១. ហេតុអ្វីបានជាដាវីឌនិងទាហានរបស់គាត់ត្រូវរស់នៅតាមជនបទ?
*(ពីព្រោះស្តេចសូលចង់សម្លាប់ដាវីឌដោយសារតែការច្រណែន)*

២. តើដាវីឌ និងទាហានរបស់គាត់បានការពារផ្ទះរបស់នរណាពីពួកចោរ? *(ណាបាល)*

៣. តើណាបាលបានឆ្លើយដូចម្តេចនៅពេលដែលដាវីឌសុំអាហារខ្លះសម្រាប់ទាហានរបស់គាត់? *(ទេ!)*

៤. តើដាវីឌចង់ធ្វើដូចម្តេចចំពោះណាបាល? *(ប្រយុទ្ធជាមួយណាបាល)*

៥. តើនរណាដែលបានបញ្ឈប់ដាវីឌមិនឲ្យវាយសម្លាប់ណាបាល? *(ប្រពន្ធរបស់ណាបាល គឺអ័ប៊ីកែល)*

៦. តើអ្នកអាចរក្សាសន្តិភាពបានយ៉ាងដូចម្តេច នៅពេលដែលនរណាម្នាក់ចង់វាយជាមួយអ្នក?
*(ត្រូវតែមានចិត្តល្អ យោគយល់អាធ្យាស្រ័យឲ្យច្រើន ។ល។)*

**៧. ល្បែងកំសាន្ត    «បញ្ជូនកូនបាល់»**

សម្ភារៈដែលត្រូវការ៖ កន្ត្រក កូនបាល់មួយចំនួន កៅអី ស្លាបព្រា



១.ចែកកុមារជាពីរក្រុមស្មើគ្នា ឲ្យពួកគេឈរជាជួរ ហើយឲ្យស្លាបព្រាទៅកុមារគ្រប់គ្នា។

២. ដាក់កៅអីពីរ និងដាក់កូនបាល់ ៥-១០ ពីលើនោះ។

៣. កុមារដំបូងគេត្រូវខាំស្លាបព្រា ហើយព្យាយាមចូកកូនបាល់ពីកៅអីដោយមិនប្រើដៃនោះទេ។ បន្ទាប់មកគេត្រូវបញ្ជូនបាល់នោះបន្តទៅកុមារបន្ទាប់ទៀត ដោយមិនប្រើដៃនោះទេ។ បន្តបញ្ជូនបាល់នោះរហូតដល់កុមារចុងក្រោយ ហើយដាក់ចូលទៅក្នុងកន្ត្រក។

៤. ប្រសិនបើពួកគេធ្វើឲ្យកូនបាល់ធ្លាក់ ពួកគេត្រូវចាប់ផ្តើមម្តងទៀត។ ពួកគេមានពេល ៥នាទីប៉ុណ្ណោះក្នុងការលេងល្បែងនេះ។ ក្រុមណាដែលបញ្ចូលបាល់ដាក់ក្នុងកន្ត្រកបានច្រើនជាងគេក្រុមនោះជាអ្នកឈ្នះ។

៥. បន្ទាប់ពីលេងល្បែងនេះចប់ សូមពន្យល់កុមារថា ការបញ្ចូលបាល់ទៅកាន់អ្នកបន្ទាប់គឺមិនងាយស្រួលនោះទេ។ ប្រហែលជាមានគ្នាយើងខ្លះក៏ខឹងដូចជាស្តេចដាវីឌដែរ។ ប៉ុន្តែដោយសារតែយើងបានប្តេជ្ញាចិត្តដើរក្នុងសន្តិភាព ដោយមិនមានការឈ្លោះប្រកែក នោះយើងនឹងអាចលេងល្បែងនេះចប់ដោយជោគជ័យ។

**៨. ខគម្ពីរចងចាំ**

**ម៉ាថាយ ៥៖៩** *"មានពរហើយ អស់អ្នកដែលផ្សះផ្សាគេ ដ្បិតអ្នកទាំងនោះនឹងបានហៅ ជាកូនរបស់ព្រះ។"*

**៩. ហត្ថកម្ម  «ព្រាបនៃសន្តិភាព»**




សម្ភារៈដែលត្រូវការ៖ សូមបោះពុម្ពរូបព្រាបទាំង៤ និងកូល័រ

១. សូមផាត់ពណ៌រូបព្រាបទាំងអស់ដោយផ្អែកទៅលើពាក្យនៅខាងលើ "សេចក្តីស្រលាញ់" "សន្តិភាព" "សេចក្តីអំណរ" និង "ពន្លឺ" ។

២. សូមរំលឹកកុមារអំពីសេចក្តីស្រលាញ់ សន្តិភាព សេចក្តីអំណរ និងពន្លឺដែលព្រះបានផ្តល់មកឲ្យពួកយើង។ ហើយក្នុងនាមយើងជាសិស្សរបស់ព្រះគ្រីស្ទ យើងគួរតែផ្តល់នូវអ្វីៗទាំងអស់នោះទៅកាន់អ្នកដែលរស់នៅជុំវិញយើងផងដែរ។

**១០. ចំរៀង** (*រើសចំរៀងខាងលើ១បទហើយច្រៀងជាមួយសិស្ស*)

**១១. អធិស្ឋាន**

**ការថ្វាយបង្គំសំរាប់គ្រូ៖ (សូមអាន ហើយអធិស្ឋានមុនពេលចាប់ផ្តើមបង្រៀន)**
ភាគច្រើននៃពួកយើងមិនចូលចិត្តជម្លោះនោះទេ តែយើងជៀសមិនរួចពីវាឡើយ។ ប៉ុន្តែដោយមានព្រះវត្តមានព្រះគង់ជាមួយយើង យើងអាចដោះស្រាយវាតាមរបៀបដែលព្រះបានបង្រៀន៖ ដោយសន្តិភាព! សូមអានព្រះគម្ពីរ **១សាំយូអែល ២៥៖១០-១៣** សារឡើងវិញ។ អ្នកប្រហែលជាមិនដើរតាមមនុស្សអាក្រក់នោះទេ ប៉ុន្តែនៅពេលដែលមាននរណាម្នាក់ប្រមាថមើលងាយអ្នក តើអ្នកនឹងឆ្លើយតបទៅគេវិញដោយកំហឹងមែនដែរឬទេ? តើអ្នកអាចដោះស្រាយជម្លោះនោះឲ្យបានល្អដោយរបៀបណា? បើយើងទុកចិត្តថាព្រះទ្រង់ជាអ្នកគ្រប់គ្រង នោះយើងអាចឆ្លើយតបដោយស្លូតបូត ពេលយើងធ្វើខុស ។

# ព្រាបនៃសន្តិភាព

ផាត់ពណ៌រូបសត្វព្រាបនីមួយៗដោយផ្អែកលើការពិពណ៌នារបស់វាមួយៗ ព្រាបនៃសេចក្ដីស្រលាញ់ សន្តិភាព សេចក្ដីអំណរ និងពន្លឺ។

សេចក្ដីស្រលាញ់



សន្តិភាព



សេចក្ដីអំណរ



ពន្លឺ

